# សិល្បៈចម្លាក់ស្បែក



រៀបរៀងដោយ នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

ឆ្នាំ ២០១៩

នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌
នាយកដ្ឋានសិល្បៈសូនរូប និង សិល្បៈសិប្បកម្ម

សៀវភៅ

# សិល្បៈចម្លាក់ស្បែក

រក្សាសិទ្ធិ ឆ្នាំ ២០១៩

# មាតិកា

ទំព័រ

អារម្ភកថា..........១

សេចក្ដីផ្ដើម..........២

I .ឥទ្ធិពលសិល្បៈចម្លាក់ស្បែកក្នុងតំបន់

១. គោលបំណង..........៤

២. គំរូស្បែកដកស្រង់ពីលោកព្រឹទ្ធាចារ្យ ពេជ្រ ទុំក្រវិល..........៤

II .ការប្រើប្រាស់ស្បែកក្នុងសង្គមមនុស្ស

ក. សម័យបុរេ១..........៣០

ខ. សម័យបុរេ២..........៣១

គ. សម័យ ស.វ ទី១-៦..........៣២

ឃ. សម័យ ស.វ ទី៧-៩..........៣២

III .បច្ចេកទេសសិល្បៈចម្លាក់ស្បែក និងការសម្ដែងសិល្បៈល្ខោនស្រមោលស្បែកធំ (វត្តរាជបូព៌)..........៣៣

IV .បច្ចេកទេសសិល្បៈចម្លាក់ស្បែក និង ការសម្ដែងសិល្បៈល្ខោនស្រមោលស្បែកធំ (សឿ វុទ្ធី)

ក. ប្រវត្តិ..........៤២

ខ. បច្ចេកទេស..........៤២

គ. ការហាលថ្ងៃ..........៤២

ឃ. របៀបព្រាងរូបលើស្បែក..........៤២

ង. ពេលដាប់ឆ្លាក់ហើយ..........៤៣

ច. តំណាម..........៤៣

V .សមាគមផ្ទះសន្តិភាព (សៀមរាប)..........៥២

VI .បច្ចេកទេសសិល្បៈចម្លាក់ស្បែក និងការសម្ដែងសិល្បៈល្ខោនស្រមោលស្បែកធំ (លោកគ្រូ ជៀន សុផាន)

ក. ប្រវត្តិ..........៦៥

ខ.បច្ចេកទេស..........៦៥

គ. របៀបដុតភ្លើងសម្ដែង..........៧១

ឃ. ពិធីរំលឹកសំពះគុណគ្រូ..........៧១

VII .បច្ចេកទេសសិល្បៈចម្លាក់ស្បែក (លោក ប្រាក់ ស៊ីផាន់ណារ៉ាត់)

ក. ប្រវត្តិ..........៨៧

ខ. សម្ភារៈបច្ចេកទេស............................................................................................................................៨៧

VIII .បច្ចេកទេសសិល្បៈចម្លាក់ស្បែកដោយលោក ញឹក សេរីរតនា (ប្រាសាទបាគង)

ក. ប្រវត្តិ...........................................................................................................................................១០៣

IX .បច្ចេកទេសសិល្បៈចម្លាក់ស្បែក និងការសម្តែងសិល្បៈល្ខោនស្រមោលស្បែកធំ (គោកធ្លក)

ក. បទបង្ហាញ.....................................................................................................................................១១៩

ខ. គោកធ្លក.........................................................................................................................................១១៩

គ. ទិសដៅ...........................................................................................................................................១១៩

ឃ. ការបង្កើតស្នាដៃក្នុងរយៈពេល១០ឆ្នាំ.....................................................................................................១១៩

ង. ការសម្តែងតាមខេត្តនានា....................................................................................................................១២០

ច. ការសម្តែងនៅរាជធានីភ្នំពេញ................................................................................................................១២០

ឆ. ទម្រង់សិល្បៈសម្តែង..........................................................................................................................១២០

X .បច្ចេកទេសសិល្បៈចម្លាក់ស្បែក និងការសម្តែងសិល្បៈល្ខោនស្រមោលស្បែកធំ (សិល្បៈសុវណ្ណភូមិ)

ក. ប្រវត្តិ...........................................................................................................................................១៣៩

ខ. រៀនឆ្លាក់ស្បែកតាមគំរូចម្លាក់ស្បែកចាស់ៗ...............................................................................................១៣៩

XI. ទីផ្សារសិល្បៈចម្លាក់ស្បែក

ក. ប្រវត្តិ...........................................................................................................................................១៦៤

ខ. បទពិសោធន៍ការងារ.........................................................................................................................១៦៤

# អារម្ភកថា

*ដើម្បីរួមចំណែកថែរក្សាអោយបានគង់វង្សនូវសម្បត្តិវប្បធម៌ជាតិ និងក្នុងគោលបំណង បន្តមរតកទាំងឡាយនេះដល់មនុស្សជំនាន់ក្រោយៗទៀតអោយបានឃើញ បានស្គាល់អំពី តម្លៃដ៏ថ្លៃថ្លាមិនអាចពណ៌នាបាននៃស្នាដៃសិល្បៈរបស់បុព្វបុរសខ្មែរយើង ទើបក្រុមការងារ សិក្សាស្រាវជ្រាវរបស់នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្មបានរិះរកគ្រប់វិធីសាស្ត្រ ដើម្បីជួបផ្ទាល់ជាមួយលោកគ្រូ អ្នកគ្រូ សិល្បករជំនាញផ្នែកចម្លាក់ស្បែក ជាពិសេសលោក គ្រូចាស់ៗ ដើម្បីប្រមូលនូវព័ត៌មានអោយបានគ្រប់ជ្រុងជ្រោយ សំរាប់ជាមូលដ្ឋានក្នុងការ សរសេររៀបចំជាឯកសារ ឬសៀវភៅស្ដីពី សិល្បៈចម្លាក់ស្បែក នេះទុកជាឯកសារយោង សំរាប់មនុស្សជំនាន់ក្រោយៗទៀតដែលចង់សិក្សាស្រាវជ្រាវបន្ត ។*

*សៀវភៅសិល្បៈចម្លាក់ស្បែក ក៏ជាទុនមួយដ៏ធំសំរាប់សិល្បករសម្ដែងស្បែកធំ ឬល្ខោន ស្រមោល និងអ្នករៀនឆ្លាក់ រៀនគូរគំនូរបុរាណ ព្រោះរូបភាពនៃផ្ទាំងស្បែកនីមួយៗបាន បានបង្កប់ទៅដោយតួអង្គក្នុងរឿងរាមកេរ្តិ៍ និងរំលេចទៅដោយក្បូរក្បាច់រចនាគ្រប់ទម្រង់របស់ ខ្មែរយើង ។*

*នៅក្នុងសៀវភៅនេះយើងបានរំលេចនូវប្រវត្តិរបស់គ្រូឯកទេស និងសិល្បករមួយចំនួន ផ្នែកចម្លាក់ស្បែកទាំងនៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ដែលជាកន្លែងធ្វើសកម្មភាព ច្រើនលើវិស័យនេះ ជាពិសេសផ្ដោតលើបច្ចេកទេសការអនុវត្តផ្ទាល់នៃក្រុមការងាររបស់ពួក គាត់នៅក្នុងសហគមន៍ ។*

*ទោះបីជាយ៉ាងណាក្ដី ក៏ការសិក្សាស្រាវជ្រាវរបស់ក្រុមការងារយើងនៅមានភាពខ្វះខាត ច្រើនទៀត ដូច្នេះដើម្បីអោយមានលក្ខណៈសុក្រឹត្យប្រកបដោយវិទ្យាសាស្ត្រ ក្រុមការងារ យើងនឹងរង់ចាំទទួលនូវមតិល្អៗពីសំណាក់អស់លោកអ្នក ។*

*សូមអរគុណ!*

រាជធានីភ្នំពេញ ថ្ងៃទី.................ខែ............ឆ្នាំ២០១៩

**ក្រុមការងារស្រាវជ្រាវ**

**នៃនាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម**

# សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាប្រទេសសម្បូរហូរហៀរទៅដោយសម្បត្តិធម្មជាតិដ៏ច្រើនសន្ធឹកសន្ធាប់ដែលជាអំណោយផលយ៉ាងសំខាន់សម្រាប់ទ្រទ្រង់ដល់ការអភិវឌ្ឍសង្គមជាតិ។ ក្រៅពីនេះអាស្រ័យដោយប្រជាជនកម្ពុជាជាអ្នកទទួលនូវឈាមជ័រសិល្បៈដ៏ឧត្តមនេះទើបបុព្វបុរសកម្ពុជាបានកសាង និងបន្សល់ទុកនូវសម្បត្តិវប្បធម៌ដ៏ច្រើនសន្ធឹកសន្ធាប់ពាសពេញផ្ទៃប្រទេស ដូចជាល្បែងរបាំ សិល្បៈតូរ្យតន្ត្រី ចម្រៀងកំណាព្យ ល្ខោនយីកេ សិល្បៈគំនូរចម្លាក់ និងសិប្បកម្មត្បាញរវៃគ្រប់ប្រភេទ។ ល។

សំណង់ប្រសាទបុរាណមាននៅគ្រប់ទីកន្លែង មានតូចមានធំទៅតាមការគោរពបូជាពិសេសតំបន់អង្គរដែលជារមណីយដ្ឋានអច្ឆិយៈនៃប្រទេសកម្ពុជា។ បច្ចុប្បន្ននេះសិល្បៈគ្រប់ទម្រង់កំពុងតែទទួលនូវបញ្ហាប្រឈមយ៉ាងធ្ងន់ធ្ងរពីសំណាក់ការរីកចម្រើននៃបច្ចេកវិទ្យាទំនើប និងការអភិវឌ្ឍនៃសង្គមជាតិតាមរយៈលំហូរចូលនៃសកលភាវូបនីយកម្ម ពីព្រោះមនុស្សយើងចង់ដឹង ចង់ឃើញ និងសាកល្បងទទួលយកនូវអ្វីដែលថ្មីទាន់សម័យ កត្តាទាំងនេះហើយដែលធ្វើអោយមានការប៉ះទង្គិចគ្នាដល់សិល្បៈវប្បធម៌ដ៏ចំណាស់របស់យើង។ ក្នុងន័យនេះ បើពុំមានការសង្គ្រោះទម្រង់សិល្បៈមួយចំនួននឹងត្រូវបាត់បង់។

## ទម្រង់សិល្បៈសូនរូប

សិល្បៈសូនរូបជាមុខវិជ្ជាមួយដែលក្នុងនោះរួមមានមុខវិជ្ជាតូចៗជាច្រើនទៀតដូចជាៈ

- គំនូរគ្រប់ប្រភេទ (បុរាណ និងសម័យ)
- ចម្លាក់គ្រប់ប្រភេទ (បុរាណ និងសម័យ)

នៅក្នុងប្រភេទនៃចម្លាក់យើងសូមលើកយកមុខវិជ្ជាចម្លាក់ស្បែកមកធ្វើការសិក្សាស្រាវជ្រាវដើម្បីឲ្យយើងទាំងអស់គ្នាបានដឹងអំពីបច្ចេកទេស និងវត្ថុធាតុដើមដែលបង្កើតឲ្យលេចជារូបរាងចម្លាក់ស្បែកសម្រាប់សម្តែងល្ខោនស្រមោល។ រីឯវិធីសាស្ត្រនៃការធ្វើស្បែកគឺយើងបានពន្យល់លំអិតនៅក្នុងសៀវភៅនេះហើយ គឺចាប់តាំងពីការហាលស្បែក ការឆ្លាក់ រួមទាំងការសម្តែងល្ខោនស្រមោលស្បែកធំ ស្បែកពណ៌ និងស្បែកតូចទៀតផង គឺងាយស្រួលយល់ដែលអាចយកមកអនុវត្តបាន។

## សិល្បៈចម្លាក់ស្បែក និងល្ខោនស្រមោល

ចម្លាក់ស្បែកជាធម្មតា គេឆ្លាក់ជារឿងតាមលំនាំនៃរឿងរាមកេរ្តិ៍ជាស្បែកធំ ស្បែកពណ៌ និងស្បែកតូចៗ

១. ស្បែកធំ ៖ សម្រាប់សម្តែងក្នុងពេលរាត្រីមានទំហំធំអាចលើកបានដោយប្រើដៃពីរជាទូទៅស្បែកធំគឺសម្តែងរឿងរាមកេរ្តិ៍។

២. ស្បែកពណ៌ ៖ ស្បែកពណ៌គឺជាស្បែកដែលគេឆ្លាក់ដូចស្បែកធំអញ្ចឹងដែរ ប៉ុន្តែរគេលាបពណ៌វា ដូចជាគំនូរបុរាណ។ ស្បែកពណ៌សម្រាប់សម្តែងនៅពេលថ្ងៃ ពីព្រោះវាមានពណ៌អាចឲ្យយើងមើលឃើញជា

ធម្មតា ដោយមិនចាំមបាច់ប្រើភ្លើងសម្រាប់បំភ្លឺដូចស្បែកធម្មតាឡើយ។
៣. ស្បែកតូច ៖ ស្បែកតូចមានទំហំតូចសម្តែងនៅពេលយប់ ជាទូទៅស្បែកតូចសម្តែងតែរឿងប្រជាប្រិយ រឿងអប់រំ ឬរឿងកំប្លុកកំប្លែងដែលធ្វើអោយអ្នកទស្សនាវីករាយជក់ចិត្តជិតអារម្មណ៍។

## ល្ខោនស្រមោល

នៅក្នុងពិភពលោកគេសង្កេតឃើញមានប្រភេទល្ខោនស្រមោលនេះច្រើនប្រទេស ដូចជា អ៊ីរ៉ង់ ភូមា ទួគី ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃ ជាដើម។ តាមការសង្កេត ល្ខោនស្រមោលទាំងនោះ ទាំងរូបរាង ទាំងការសម្តែង ជើត ពោល និងតន្ត្រី ឃើញថាខុសគ្នាទាំងអស់ទៅតាមលក្ខណៈធម្មជាតិ និងទំនៀមទម្លាប់ប្រពៃណីនៃប្រទេសនីមួយៗ។

តាមការប៉ាន់ស្មាន គឺសិល្បៈល្ខោនស្រមោល ឬសិល្បៈស្បែកធំ និងតូចទាំងនេះហើយដែលឲ្យកំណើតមកសិល្បៈភាពយន្តសព្វថ្ងៃនេះ។ ចំណែកនៅកម្ពុជាវិញ មានសិល្បៈល្ខោនស្រមោលនេះ ៣ ប្រភេទគឺ សិល្បៈស្បែកធំ សិល្បៈស្បែកតូច និងស្បែកពណ៌ ដែលមានឈ្មោះប្រជាប្រិយហៅថា អាយ៉ង ហើយមានលក្ខណៈពិសេសខុសពីសិល្បៈល្ខោនស្រមោលនៃជាតិដ៏ទៃទៅតាមចរិតលក្ខណៈទំនៀមទម្លាប់ប្រពៃណីរបស់ជាតិកម្ពុជាសុទ្ធសាធ។

សិល្បៈស្បែកធំគឺជាចម្លាក់នៅលើស្បែកគោ ដែលមានទំហំរហូតដល់ជាង ២ម៉ែត្រការ៉េហើយមានផ្ទាំងខ្លះមានទម្ងន់រហូតដល់ ៨គីឡូក្រាម។ រូបចម្លាក់ស្បែកធំនេះជាចម្លាក់នឹងផ្តល់គ្មានចលនាទេ ហើយខុសពីស្បែកតូចដែលមានទំហំតូចៗ និងជារូបចម្លាក់ដែលមានចលនារស់រវើក អាចបត់ដៃជើង ឬហាមាត់និយាយបាន។

តាមការសិក្សាស្រាវជ្រាវអាចធ្វើឲ្យយើងដឹងថា សព្វថ្ងៃនេះស្បែកធំកម្ពុជាដែលប្រជាជនកម្ពុជាបានថែរក្សាទុកឲ្យគង់វង្សនោះ មាននៅខេត្តសៀមរាប និងនៅរាជធានីភ្នំពេញ។

ក្នុងមួយឈុតៗនៃសិល្បៈស្បែកធំរបស់ខ្មែរមានចំនួយស្បែក ១៥៤ផ្ទាំង ដែលយើងអាចចែកចេញជា ៥សណ្ឋានដូចតទៅ ៖

១. មនុស្សប្រុស (ក្សត្រា)

២. មនុស្សស្រី (ក្សត្រី)

៣. យក្ស

៤. ស្វា និងសត្វដទៃ

៥. មនុស្សប្រុស ស្រី (ប្រជាជន)

ម្យ៉ាងទៀត ក្នុងចំនួនស្បែកទាំងជាង ១៥៤ផ្ទាំងនេះ មានការតុបតែងលំអរចនាដោយលក្ខណៈប្លែកៗគ្នាវិវត្តន៍ទៅតាមកាលៈទេសៈ និងទីកន្លែងប្រព្រឹត្តទៅរបស់សាច់រឿង និងប្រកបដោយចលនាខុសៗគ្នាជាច្រើនដែលយើងសង្កេតឃើញជាទូទៅមានចលនាសំខាន់គឺ ៖ ដើរ, ហោះ, ច្បាំង, តាំងសីល, ទុក្ខព្រួយ, ដំណើរកំសាន្ត, ប្រជុំ(គាល់), ប្រែក្រឡា, ស្នេហា, ធម្មជាតិ, ជីវភាពប្រជាជនជាដើម។

# I. ឥទ្ធិពលសិល្បៈចម្លាក់ស្បែកក្នុងតំបន់

## ១. គោលបំណង

- គោលបំណង ១៖ យើងបានថែរក្សានូវទំរង់សិល្បៈចម្លាក់ស្បែកនេះតាំងពីបុរាណរហូតមកដល់បច្ចុប្បន្ន ហើយបន្តថែរក្សា លើកកម្ពស់ផ្សព្វផ្សាយសំរាប់ពេលអនាគតទៀត។
- គោលបំណង ២៖ ក្នុងន័យខ្វាចបាត់បង់យើងខ្ញុំប្រឹងប្រែងឲ្យអន្តរជាតិជួយយើងដើម្បីដាក់ល្ខោនស្រមោលស្បែកធំ របស់យើងទៅក្នុងបញ្ជី បេតិកភណ្ឌវប្បធម៌នៃមនុស្សជាតិនៃអង្គការ UNESCO កាលពីឆ្នាំ ២០០៥។
- គោលបំណង ៣៖ ចម្លាក់ស្បែករបស់យើង បច្ចុប្បន្ននេះឃើញមានការរីកចំរើន ច្រើនកន្លែងពិសេសនៅរាជធានីភ្នំពេញ និងខេត្តសៀមរាមដូច្នេះ គឺយើងចង់ដឹងពីការវិវត្តន៍នៃការផារបច្ចេកទេសរបស់ពួកគាត់។
- គោលបំណង ៤៖ គឺឲ្យពួកគាត់បានជួបជុំគ្នាពិភាក្សាគ្នាដើម្បីផ្លាស់ប្តូរនូវ បទពិសោធន៍ពីគ្នាទៅវិញទៅមកតាមរយៈការធ្វើបទបង្ហាញ។
- គោលបំណង ៥៖ ធ្វើឲ្យពួកគាត់មានគំនិតច្នៃប្រឌិតប្លែកៗដើម្បីបង្កើតស្នាដៃសិល្បៈថ្មីៗប្រកបដោយសោភ័ណ្ឌភាព និងគុណភាព ។ កាលណាស្នាដៃល្អគឺពួកគាត់អាចរកទីផ្សាបានរួមចំណែកដល់សេដ្ឋកិច្ចគ្រួសារ និងវប្បធម៌។

## ២. គំរូស្បែកដកស្រង់ពីលោកព្រឹទ្ធចារ្យ ពេជ្រ ទុំក្រវិល



ឥន្ទជីតនាំយក្សសុក្កាចាត្រូវជាកូនរបស់ពិភេកឲ្យក្លែងខ្លួនជានាងសេតា



ឥន្ទជិតក្លែងខ្លួនជាព្រះឥន្ទ្រ



ឥន្ទជិតគង់លើដំរីឰភ័វនបាញ់សម្លាប់ព្រះលក្ស្មណ៍



ពលយក្ស



ព្រះរាមទ្រង់ព្រះកន្សែងអោបសពនាងសិតា



ហនុមានចាប់នាងបុញ្ញកាយ



ហនុមានថែចងនាងបុញ្ញកាយ



ឥន្ទជិតតាំងសិល្ប៍



ផ្ទាំមឿង. ឥន្ទជិតយំលានាងសុវណ្ណកាន់មយូរ៉ាជាចុងក្រោយ



ក្រុងរាពណ៍យំលានាងមន្ទោគិរីជាចុងក្រោយ



ឥន្ទជិតប្រយុទ្ធជាមួយព្រះលក្ស្មណ៍


ព្រះលក្ស្មណ៍ត្រូវសរឥន្ទជិត


ព្រះលក្ស្មណ៍ត្រូវសរដួលសន្ធប់



ព្រះរាមដកសរពីព្រះលក្ស្មណ៍តែពុំរួច



ហនុមានទៅរកថ្នាំផ្ដាច់សរព្រះលក្ស្មណ៍តែត្រូវកង់ចក្ររបស់រុក្ខទេវតា



ពិភេកផ្សំថ្នាំផ្គាប់សរវេទ្ធជិត



ពិភេកបង្កាត់សរព្យាបាលព្រះលក្ស្មណ៍



ឥន្ទជិតត្រូវសរពាន់ព្រះលក្ស្មណ៍



ស្បែកពណ៌



រូបតួអង្គប្រុសដើរ ឬ(ក្សត្រាយាង)



រូបតួអង្គស្រីដើរ ឬក្សត្រីយ៍យាង



ភិភេកច្បាំងដណ្ដើមនាងសិតា



ការប្រលងរិទ្ធលើកធ្នូជ័យដើម្បីយកនាងសិតា




ក្រុងរាពណ៍ចាប់នាងសេតា



ពាលីប្រយុទ្ធជាមួយសុគ្រីព



ហនុមានចាប់នាងបុញ្ញកាយ



ហនុមានថែចង់នាងបុញ្ញកាយ



ហនុមានបញ្ជិះព្រះរាមព្រះលក្ស្មណ៍ឆ្លងកាត់សមុទ្រ



ការធ្វើដំណើរ និងឧបសគ្គតាមផ្លូវរបស់ព្រះរាមព្រះលក្ស្មណ៍ និងនាងសេតា



ក្បួនទ័ព



ចម្លាក់ឈើរឿងរាមកេរ្តិ៍



គំនូរបុរាណវត្តបូព៌ ខេត្តសៀមរាប





គំនូរបុរាណខ្មែរ និងរបាំ



កិន្នរីក្បាច់ទម្ពុះ



គំនូរលើឈើ



គំនូរលើឈើពិតាន វត្តមហាលាភ កំពង់ចាម





ការប្រើប្រាស់ក្បាច់ក្នុងសិល្បៈគំនូរ និងចម្លាក់



ក្បាច់ភ្ញីភ្លើង



ក្បាច់ភ្ញីទេស (សារមន្ទីរជាតិ)



ហោជាងក្បាច់ភ្ញីទេស





ហោជាងក្បាច់ភ្ញីទេស ព្រះបរមរាជវាំង



ក្បាច់ភ្ញីវល្លិ៍ (អង្គរវត្ត)



ក្បាច់ភ្ញីអង្គរ (ផ្ដែ)



ចម្លាក់ផ្តេ



ចម្លាក់រឿងរាមកេរ្តិ៍ប្រាសាទអង្គរវត្ត



ចម្លាក់រឿងរាមកេរ្តិ៍ប្រាសាទអង្គរវត្ត





ចម្លាក់ឧឈើបិទមាសរឿងរាមកេរ្តិ៍ វត្តដំណាក់ ខេត្តសៀមរាប



ចម្លាក់បាយអរ វត្តដំរីស ខេត្តបាត់ដំបង



ចម្លាក់បាយអ រឿងរាមកេរ្តិ៍ (វត្តដំរីស)



សុគ្រីពឃាត់ហនុមាន និងនីលផាត់ឈ្លោះគ្នា



សុគ្រីព ប្រយុទ្ធជាមួយពាលី (ប្រាសាទបន្ទាយស្រី)

## II. ការប្រើប្រាស់ស្បែកក្នុងសង្គមមនុស្ស

### ក. សម័យបុរេ១






## ខ. សម័យបុរេ២



ការរស់នៅជាកុលសម្ពន្ធ័របស់មនុស្សជំនាន់ដើម

## គ. សម័យ ស.វ ទី១-៦



សម្លៀកបំពាក់ខ្មែរសម័យបុរេប្រវត្តិសាស្ត្រ

## ឃ. សម័យ ស.វ ទី៧-៩



សម័យចេនឡា

## III. បច្ចេកទេសសិល្បៈចម្លាក់ស្បែក និងការសម្ដែងសិល្បៈល្ខោនស្រមោលស្បែកធំ (វត្តរាជបូព៌)

*ក្រុមសិល្បៈឆ្លាក់ស្បែក និងសម្ដែងស្បែកបានបង្កើតឡើងនៅឆ្នាំ ១៩៨៥ នៅជុំរុំជនភៀសខ្លួនព្រំដែនខ្មែរថៃ ដោយលោកគ្រូ **ពិន សែម** ព្រះចៅអធិការវត្តបូព៌ លុះដល់ឆ្នាំ ១៩៨៨ បានធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញដោយនាំយកក្រុមសិល្បៈទាំងនោះចូលមកស្រុកខ្មែរវិញ ដែលមានទីតាំងនៅវត្តបូព៌ ខេត្តសៀមរាម។*

*តាមរយៈការបណ្ដុះបណ្ដាលពីលោកគ្រូ **ពិន សែម** ធ្វើឲ្យសិស្សចេះគូរ ឆ្លាក់ និងសម្ដែងស្បែកបានយ៉ាងល្អ ដោយយោងទៅលើឯកសារគំនូរបុរាណ នៃព្រះវិហារវត្តបូព៌។*

*ស្បែកនៅវត្តបូព៌មានទំហំធំជាងស្បែក នៃក្រុមសិល្បៈដទៃទៀតនៃប្រទេសកម្ពុជា បច្ចុប្បន្នបានសម្រួលឲ្យមើលឃើញច្បាស់។ ស្បែកដើតមានទម្ងន់ធ្ងន់ត្រូវសម្រួលទៅតាមខ្នាតនៃគំនូរបុរាណ។*

*កាលពីសម័យបុរាណ វង់ភ្លេងនៅចំកណ្ដាលឆាក បច្ចុប្បន្នសម្រួលឲ្យមកនៅកៀនឆាក។*

*បានបណ្ដុះបណ្ដាលសិស្សជាច្រើននាក់ ភាគច្រើនជាក្មេងវត្ត និងបន្តជ្រើសរើសជារៀងរហូត។*

*ឧបករណ៍ភ្លេង ៖ មាន រនាត ស្គរ គង សាឡៃ ។*

*ស្បែក៖*

*- ស្បែកធំ សម្ដែងរឿងរាមកេរ្តិ៍ ព្រហ្មញ្ញសាសនា*

*- ស្បែកតូច សម្ដែងរឿងប្រជាប្រិយ*

*-ក្រុមសិស្សករវត្តបូព៌ បណ្ដុះបណ្ដាល និងផ្សព្វផ្សាយជំនាញសិល្បៈមិនធ្វើអាជីវកម្មទេ។*



*សិក្ខាសាលាស្ដីអំពីការសម្ដែងស្បែកធំ*




របៀបដើតស្បែក



របៀបដំណើរដើតក្បូនទ័ព



របៀបបង្ហំគល់



ក្រុមភ្លេង



ការផ្ទេរចំណេះដឹងសិល្បៈដល់យុវជន



របៀបដើតស្បែក



ព្រះរាមផ្ទៃធ្នូសរ



ព្រះរាមគង់លើរាជរថ



រូបព្រះរាម ឬព្រះលក្ស្ម័ណ៍ទ្រង់យាង



រូបព្រះរាមគង់លើរាជរថទ្រង់ចូលសមរភូមិ



ព្រះលក្ស្ម័ណ៍បង្គំគាល់



ពិភេកហោភ



និលផាត់គង់លើភជសីហ៍



និលឯក

## IV. **បច្ចេកទេសសិល្បៈចម្លាក់ស្បែក និង ការសម្តែងសិល្បៈល្ខោនស្រមោលស្បែកធំ (សឿ ឌុន្នី)**

*ក. ប្រវត្តិ*



-កើតនៅឆ្នាំ ១៩៦០ នៅភូមិព្រិជ ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ។

- ឆ្នាំ ១៩៧១ រៀនសិល្បៈ នៅសាលាល្ខោនជាតិ (សាកលវិទ្យាល័យភូមិវិចិត្រសិល្បៈ)។

- ១៩៧៩ ចូលបំរើការងារនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រហូតមកដល់បច្ចុប្បន្ន ។

-ជាអ្នកតម្លើងស្នាដៃ និងជាអ្នកសម្តែង ស្នាដៃសិល្បៈទស្សនីយភាព។

- ១៩៧២ - ៧៣ បានរៀនវិជ្ជាចម្លាក់ស្បែកពីលោកគ្រូណាត់, ឌិប, រិន កេង នៅខេត្តសៀមរាប។

- បង្ហាត់នៅភ្នំពេញ ដល់ឆ្នាំ ១៩៧៥ រៀនក្រៅម៉ោង។

*ខ. បច្ចេកទេស*

- រកទីធ្លា៖ វាល មានស្មៅខ្ចីៗ យកស្បែកទាំងមូល ៥០ – ៦០kg យកស្បែកដាក់លើដីរាបស្មើសម្រួចឬស្សីធ្វើជាស្នឹង ចោះជារន្ធចម្ងាយ២តឹកពីគ្នា ដោយយកស្នឹងវាយចូលដីទាញបន្តឹងស្បែក។

- សំអាត៖ យកកាំបិតចៀរយកសាច់ខ្លាញ់ចេញ យកទឹកជះលាងបើឈាមនៅជាប់ញើវាឲ្យចូលក្នុងស្បែកដើម្បីយកពណ៌ក្រហម យកកាំបិតមុតសំអាតឲ្យស្អាត។

*គ. ការហាលថ្ងៃ*

- ហាលថ្ងៃក្តៅ អាកាសធាតុល្អ ហាលរយៈពេល៥ថ្ងៃ

- រួចយើងយកស្បែកមកកោសរោមយកកាំបិតបន្ទួសមកកោស ឬប្រើ (Moteur) ត្រូវរកប្រដាប់ការពារមុខ Mask

- ហាលថ្ងៃឲ្យស្រពាប់យកទឹកកណ្តោល, ស្វែង ត្រាំសំបកក្នុងពាង ១សប្តាហ៍ ស្ងោររម្ងាស់ទឹក៣ យកទឹក១

- យកទឹកកណ្តោលនោះមកលាបពីលើស្បែកឲ្យសព្វរួចទុកឲ្យស្ងួត។

*ឃ. របៀបព្រាងរូបលើស្បែក*

យកម្សៅសលាយទឹក ឬ Spetro យកឬសដើមរំចេក ដំធ្វើជាជក់គូ(កាលពីសម័យបុរាណ) ឬជក់ចិន (បច្ចុប្បន្ន)។ ព្រាងលើក្រដាសក៏បាន បិតជាប់ស្បែក ឬព្រាងលើស្បែកដោយផ្ទាល់ យកស្បែកទៅដាប់ឆ្លាក់ ជារូបភាពពិសេសរឿងទេវកថា រាមកេរ្តិ៍ ឆ្លាក់ជាក្បាច់ផ្កាភ្ញី ជាតួអង្គសាច់រឿងភាពផ្សេងៗ ។ល។

### ង. ពេលដាប់ឆ្លាក់ហើយ

- ត្រូវយកក្រណាត់ជ្រលក់ទឹកកណ្ដាលលាបពីលើស្បែកឲ្យសព្វ។
- រួចបានយើងគូរសសៃពណ៌ខ្មៅលាបឲ្យឃើញរូបច្បាស់ ឬហៅម្យ៉ាងថា កាត់សសៃខ្មៅ ដោយប្រើទឹកខ្មៅដុសចិន (Encre de Chine)។
- យកបន្ទះឫស្សីដែលបិតច្រៀកឲ្យស្អាត យកមកគៀបឲ្យជាប់ ដោយយកស្បែកច្រៀកជាចំណង ឬវល្លិ៍លំពាក់ ផ្ដៅចងសម្រាប់កាន់សម្ដែង។

### ច. តំណម

- កុំដើរកន្លងលើស្បែក
- គោរព តាឥសី
- ព្រះឥសូរ ដាក់តាំងខ្ពស់ជាងគេ។
- រៀបចំអសនៈគោរព ព្រះគ្រូ។ល។
- សែនព្រេន ផ្លែឈើ នំនែក ទឹក ។ល។



សកម្មភាពរៀបចំស្បែកសម្រាប់ថត



សកម្មភាពរៀបចំស្បែកសម្រាប់ថត



ព្រាងរូបលើស្បែក



ការតាំងបង្ហាញស្បែក



ឥន្ទជិតគង់លើរាជរថ



សម្ពលីគ្រុឌបំផ្លាញសនាគកប្បាស



នាងប៊ុញកាយប្រែកាឡាជាសពនាងសិតាអណ្តែតទឹក



អង្គត់



ហនុមាន



ឥន្ទជិតពួនក្នុងដុំពពកខ្មៅ



ព្រះរាមគង្គក្នុងព្រះពន្លា



សុគ្រីព



ព្រះរាមទ្រង់ព្រះកន្សែង



សហសកុមារ



ព្រះលក្ស្មណ៍ និងពលស្វាត្រូវសនាគកប្បាស



ព្រះរាមទ្រង់យាត្រា

## V. សមាគមផ្ទះសន្តិភាព (សៀមរាប)







*សមាគមផ្ទះសន្តិភាពគឺជាកន្លែងបណ្តុះបណ្តាលសិល្បៈចម្លាក់ស្បែក និងសិប្បកម្មសិល្បៈដ៏ទៃទៀតក្នុងខេត្តសៀមរាប*




ប្រវត្តិសមាគម និងការឧបត្ថម្ភទ្រទ្រង់សមាគម



គំនូរស្បែកលើជញ្ជាំង





គំនូរស្បែកលើជញ្ជាំង



គំនូរស្បែកលើជញ្ជាំង



គំនូរស្បែកលើជញ្ជាំង



គំនូរស្បែកលើជញ្ជាំង



គំនូរស្បែកលើជញ្ជាំង



គំនូរស្បែកលើជញ្ជាំង



តុតាំងស្បែក



វត្ថុអនុស្សាវរីយ៍ធ្វើអំពីប្រាក់


សាលពិពរ័ណ៌


ពោងដាំងចម្លាក់ស្បែក



ព្រះរាមផ្ទៃងសរ





រូបអាយ៉ង


ស្វាប្រចាប់


ហ្មដំរី



ស្វាប្រចាប់



ហនុមានហោះ



ហនុមានបង្គំគាល់



ដើមពោធិ



រូបយក្ស និងតួស្រីដើរ



រូបនាងបុញ្ញកាយប្រែកាឡាជាសពនាងសិតា



ទេវតាផ្ទុំស័ង្ខ



គ្រោងហាលស្បែក

## VI. បច្ចេកទេសសិល្បៈចម្លាក់ស្បែក និងការសម្តែងសិល្បៈល្ខោនស្រមោលស្បែកធំ (លោកគ្រូ ជៀន សុផាន)

*ក. ប្រវត្តិ*



- លោក គ្រូ ជៀន សុផាន កើតនៅឆ្នាំ ១៩៧៨ នៅភូមិសាលាកន្សែង ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប។
- ឆ្នាំ១៩៩៣ បានទទួលការបណ្តុះបណ្តាលពីលោកគ្រូ ទី ជៀន, លោកគ្រូ ណាប់ ពៅ។
- រៀនគូរ រៀនធ្វើដែកឆ្លាក់ រៀនដាប់ រៀនឆ្លាក់ រៀនហាលស្បែក និងរៀនលាបពណ៌។
- បានបណ្តុះបណ្តាលផ្ទេរចំណេះដឹងដល់សិស្សបានចំនួន ២៧ នាក់ បច្ចុប្បន្ននេះ សិស្សទាំងឡាយនោះបានបន្តអាជីពចម្លាក់ស្បែកនៅគ្រប់ទីកន្លែង។
- ស្នាដៃដែលផលិតបានគឺសម្រាប់ សម្តែង និងសម្រាប់ទីផ្សារ។
- ការសម្តែងតាមការបញ្ជា (Order) របស់ភ្ញៀវជាតិ និងអន្តរជាតិគឺរៀងរាល់ចុងសប្តាហ៍។

*ខ.បច្ចេកទេស*

- ស្បែកធំគឺសម្តែងរឿងរាមកេរ្តិ៍
- ស្បែកតូច សម្តែងរឿងព្រេងនិទាន រឿងប្រជាប្រិយ
- ស្បែកពណ៌សម្តែងនៅពេលថ្ងៃ(មានគម្រោងនឹងបង្កើតនៅពេលខាងមុខ) និងត្រូវការអ្នកជំនាញគំនូរបុរាណដើម្បីជួយក្នុងកិច្ចការនេះ។

*របៀបធ្វើស្បែក*

- បច្ចេកទេសនៃការធ្វើស្បែក និងការដាប់ឆ្លាក់ គឺស្ថិតនៅលើសិល្បករជាអ្នកអនុវត្តផ្ទាល់
- ស្បែកគោស្រស់ហាលថ្ងៃ ធ្វើស្បែកដោយខ្លួនឯងទើបស្គាល់ស្បែកច្បាស់ ប្រសើជាងទិញស្បែកដែលគេហាលស្ងួតស្រាប់ ស្បែកកាលណាហាលមិនស្ងួតធ្វើឲ្យស្បែករួញ ហាមត្រូវទឹក ហាលមួយសន្ទុះទើបលាបដំរកណ្តោល លាបដំរកណ្តោលពេលស្បែកនៅសើមតិចៗដើម្បីឲ្យដំរជ្រាបទើបហាលថ្ងៃ។

*វត្ថុធាតុដើម*

- វត្ថុធាតុដើមរួមមាន សំបកដើមកណ្តោល ស្តៅ ស្វាយចន្ទី ស្ងោទឹកបី យកទឹកមួយ
- ដាប់ ឬឆ្លាក់ស្បែកហើយត្រូវលាងស្បែកនឹងទឹកសាប៊ូដុំ (សាប៊ូផ្គាប) រួចហើយលាងទឹកសាប៊ូចេញបន្ទាប់មកហាលថ្ងៃឲ្យស្ងួតល្មម ដើម្បីលាបទឹកកណ្តោលម្តងទៀត រួចលាបទឹកខ្មៅដុសចិន ឬជប៉ុន (Encre de chine) ។

### របៀបចម្រាញ់ទឹកខ្មៅ

- ទឹកខ្មៅដុសចិន ឬជប៉ុនដាំទឹកឲ្យពុះស្ងោឲ្យរលាយទឹកបីយកទឹកមួយ ទុកឲ្យត្រជាក់រួចទើបយកមកគូរ។

### ការសម្តែង

- ការសម្តែងសិល្បៈត្រូវស្លៀកពាក់អាវកត្រង់ សំពត់ចងក្បិន ក្រមាក្រវ៉ាត់ចង្កេះ។
- ក្រុមសិល្បករ ២០នាក់មកពីគ្រប់ទីកន្លែង ក្រុមនេះអាចសម្តែងបានទាំងទម្រង់សិល្បៈបុរាណ និងសិល្បៈសម័យ គឺអាចឆ្លាក់ស្បែកក៏បាន សម្តែងល្ខោនស្រមោលក៏បាន។



សម្ភារៈ សម្រាប់ឆ្លាក់ស្បែក



សម្ភារៈសម្រាប់គូរ



លោកគ្រូ ទី ជៀន




រោងសម្តែងសិល្បៈស្បែកធំក្រុមលោកតា ទី ជៀន



បន្ទប់ថែរក្សារស្បែក





វិធីសាស្ត្រនៃការសម្ងាប់ស្បែកគោ



ឧបករណ៍ភ្លេងសម្រាប់សម្តែងស្បែក



បន្ទប់សម្តែង



ដង្វាយគ្រូ



សាកល្បងពន្លឺ



រៀបតួអង្គត្រៀមសម្ដែង

### គ. របៀបដុតភ្លើងសម្ដែង

តាមក្បួនបុរាណគឺគេយកត្រឡោកដូង និងចន្ទុះជ័រឈើ ធ្វើចង្ក្រាន ធ្វើខ្នោះ ដុតភ្លើង។ ពេលសំដែង ឲ្យឃើញតែភ្លើងប៉ុណ្ណោះ ដាក់ដើមចេក ដាក់ដីពីលើ រៀបត្រឡោក ថែមត្រឡោកពេលសំដែងរហូតដល់ចប់ (អាស្រ័យលើម៉ោងសំដែងខ្លី ឬវែង)។ បច្ចុប្បន្ននេះ ដោយបច្ចេកវិទ្យាទំនើប គេប្រើភ្លើងអគ្គិសនីជំនួសវិញ។

- ស្បែកធំ ៖ មានទំហំធំសម្រាប់សម្ដែង រឿងរាមកេរ្តិ៍ មានគ្រប់ឈុត។
- ស្បែកតូច ៖ អាចកំរើកបាន សម្ដែងរឿងព្រេង រឿងកំប្លុកកំប្លែង រីឯអ្នកសម្ដែងលាក់ខ្លួនខាងក្នុងមិនឲ្យឃើញ គឺឲ្យឃើញតែសាច់រឿង។
- ស្បែកពណ៌ ៖ គេគូរដាក់ពណ៌នៅលើស្បែកដែលគេឆ្លាក់ហើយ គឺសម្រាប់សម្ដែងនៅពេលថ្ងៃ។

### ឃ. ពិធីរំលឹកសំពះគុណគ្រូ

គ្រូជាអ្នកបង្រៀនយើង យើងរំលឹកដល់គាត់ គាត់ជាអ្នកអប់រំ និងបញ្ចូលការអប់រំក្នុងសាច់រឿងដើម្បីណែនាំមនុស្សឲ្យដើរក្នុងផ្លូវល្អ។

ព្រះពុទ្ធ ព្រះមុន្នីឥសី ព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះពិស្នុការ ជាព្រះគ្រូអប់រំប្រៀនប្រដៅឲ្យមនុស្សសត្វទាំងឡាយកសាងនូវអំពើល្អក្នុងផ្លូវធម៌។

- ដង្វាយ ៖ បាយសី ស្លា ម្លូ ទៀន ធូប ផ្លែឈើ សុរា ភេសជ្ជៈ ។ល។

នមស្សការ នមោតស្ស បីចប់ ... យក្សអរ ...!

- ឧបករណ៍ភ្លេង (ពិណពាទ្យ)៖ រនាតឯក រនាតធុង គងតូច គងធំ សំភោ ស្គរតូច ស្គរធំ ស្រឡៃតូចធំ។
- បទភ្លេង ៖ បទយក្សដើរ បទមនុស្សដើរ បទស្វាដើរ បទក្រៀមក្រំ និងបទភ្លេងផ្សេងៗទៀត។



រូបព្រះរាមផ្ទៃធំសរ ស្បែកចាស់



ឥន្ទជិតថ្វៃធ្នូសរ



ពលស្វាជិះខ្លា


ព្រះរាម ថ្ងៃផសរ


ព្រះរាមគង់ក្នុងព្រះពន្ធាជ័យ



ព្រះរាមថ្លៃធ្នូសរ



ការរៀបចំស្បែកសំរាប់សម្តែង



ព្រះរាមយាងចូលសមរភូមិជ័យ



សិម្ពលីគ្រុឌជួយសង្គ្រោះព្រះលក្ស្មណ៍



ព្រះលក្ស្មណ៍ប្រយុទ្ធជាមួយឥន្ទជិត



ឥន្ទជិតយាងចូលសមរភូមិជ័យ



ឥន្ទជិតប្រែក្រឡាជាព្រះឥន្ទ្រគង់លើដំរីឰរ៉ាវ័ន



សុគ្រីពមេទ័ពស្វា


ព្រះមុនីឥសី សម្ដេចព្រះគ្រូធំ



ព្រះរាមទ្រង់ព្រះកន្សែង



ពិភេកយាត្រា



ពលសេនាយក្សបង្គំគាល់



នាងបុញ្ញកាយហោះ



នាងបុញ្ញកាយប្រែក្រឡាជាសាសពនាងសិតាអណ្តែតទឹក



ព្រះលក្សណ៍ទ្រង់បង្គំគាល់



សុគ្រីពបង្គំគាល់



កងល្បាតសេនាយក្ស



វិរុលកុមារ



ស្វាស ស្វាខ្មៅ (ហនុមានចាប់និលផាត់)



ទេវតាគង់លើសត្វឥន្ទ្រី



សុគ្រីព



ហនុមាន



តួត្លុកកំប្លែង



តួត្លុកកំប្លែង



ព្រះរាមទ្រង់យាត្រា



ស្បែកតូច



តួប្រជាជនសាមញ្ញ

## VII. **បច្ចេកទេសសិល្បៈចម្លាក់ស្បែក (លោក ប្រាក់ ស៊ីផាន់ណារ៉ាត់)**

### *ក. ប្រវត្តិ*



*- លោក ប្រាក់ ស៊ីផាន់ណារ៉ាត់*

*កើតនៅឆ្នាំ ១៩៥៨ សង្កាត់លេខ ៦ ភ្នំពេញ*

*- លំនៅបច្ចុប្បន្ន ភូមិព្រៃកល្វា ឃុំព្រៃកតាគូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។*

*- ចូលរៀននៅ ព្រះបរមរាជវាំង ផ្នែករបាំ ព្រះរាជទ្រព្យ (តួស្វា)។*

*- ឆ្នាំ ១៩៧២ រៀននៅសកលវិទ្យាល័យ ភូមិ និងវិចិត្រសិល្បៈផ្នែក របាំប្រពៃណី (តួស្វា ក្បាច់ល្ខោនខោល) ហនុមាន។*

*-ល្ខោនខោលមាននៅ វត្តស្វាយអណ្តែត ខេត្តកណ្តាល និងខេត្តបាត់ដំបង។*

*- បានរៀនរបាំប្រពៃណី និង ល្ខោន ស្រមោលស្បែក (សម្តែងផង ចម្លាក់ផង និងសិល្បៈទូទៅ បាសាក់ យីកេ មហោរី។ល។*

*- ១៩៨០ - ១៩៨១ ផលិតស្បែកនៅខេត្តកំពង់ធំ ជាមួយលោកតា ដឹប ជាគ្រូសិល្បៈបំរើការងារនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ ក្រោមការដឹកនាំរបស់លោកព្រឹទ្ធាចារ្យ ឆេង ផុន។*

*- ឆ្នាំ២០១២ បានចូលរួមតាំងពិព័រណ៍សិល្បៈចម្លាក់ ស្បែក នៅប្រទេសកូរ៉េ។*

### *ខ. សម្ភារៈបច្ចេកទេស*

*- ដើមកន្ទ្រាំងបាយសធ្វើជាដក់គូរ*

*- កំបោរសសម្រាប់គូសព្រាងរូប*

*- ខ្មៅដុសចិន*

*- បណ្តូលថ្មពិល មកដំឲ្យម៉ដ្ឋ ទ្រាំទឹករួចយកមកគូរ (ឬហៅម្យ៉ាទៀតថា កាត់ជាសសៃ)*

*- ស្បែកគោ សម្ងាប់នឹងកំដៅថ្ងៃ*

*- ដើមសំបកកណ្តោល ទឹក៣យកទឹកមួយ*

*បច្ចុប្បន្ននេះ លោក ប្រាក់ ស៊ីផាន់ណារ៉ាត់ បានឆ្លាក់ចម្លងតាមស្បែក ចាស់ៗទាំងអស់ចំនួន ៩០ សន្ទឹក ក្រោមព្រះរាជឧបត្ថម្ភ ពីសម្តេចម៉ែ ឆ្នាំ២០១៩ (ប្រើរយៈពេល មួយឆ្នាំ៣ខែ)*

*- ឆ្លាក់ជូនទៅ ខេត្តបន្ទាយមានជ័យ ចំនួន១៨៦សន្ទឹក*

*- បច្ចុប្បន្នជាជំនួយការបង្រៀនផ្នែកចម្លាក់ស្បែកនៅសាលាមធ្យមវិចិត្រសិល្បៈ*

*- លោកខិតខំប្រឹងប្រែងធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីលើកស្ទួយវិស័យសិល្បៈ វប្បធម៌ជាតិ។*



ដើមកណ្ដោល



សំបកកណ្ដោល



ពាងសំរាប់ត្រាំសំបកកណ្ដោល



ការត្រាំសំបកកណ្ដោល



វិធីស្ងោររម្ងាស់សំបកកណ្ដោល





ការចំរ៉ាញ់ទឹកបី យកទឹកមួយ



ការចំរ៉ាញ់ទឹកបី យកទឹកមួយ



វិធីថែទាំស្បែកគោ



វិធីថែទាំស្បែកគោ



*ពេជជាងចម្លាក់ស្បែក*







*រូបភាពស្បែកផ្សេងៗ*



នាងសេតាគង់ក្នុងបុស្សបុក ឆ្លាក់ថ្មីតាមគំរូចាស់



ព្រះនាងសេតាគង់ក្នុងបុស្សបុក រូបដើម




រូបភាពលំអិត អំពីស្បែកចាស់




រូបភាពលំអិត អំពីស្បែកចាស់



រូបភាពលំអិតក្បាច់រចនា



រូបភាពលំអិត រូបមនុស្សនិងគ្រឿងលំអ



ព្រះព្រហ្ម



ស្បែកពណ៌ រូបឥន្ទជិតចូលសមរភូមិ



សុគ្រីពហោះ



សេនាយក្ស



អង្គត



ហនុមា



ហនុមានប្រយុទ្ធជាមួយយក្ស



នាងបុញ្ញកាយហោះ



សេនាយក្ស



សពនាងសិតាអណ្តែតទឹក



ស្បែកចាស់ រូបភីលៀង



សិល្បៈករនិងស្នាដៃ

## VIII. បច្ចេកទេសសិល្បៈចម្លាក់ស្បែកដោយលោក ញ៉ឹក សេរីរតនា (ប្រាសាទបាគង)

*ក. ប្រវត្តិ*

*- លោក ញ៉ឹក សេរីរតនា*

*- កើតនៅឆ្នាំ១៩៧៦ នៅស្រុកបន្ទាយស្រី ខេត្តសៀមរាប។*

*ជាក្មេងកំព្រា ធ្លាប់ដើររើសសំរាម អេតចាយ បានខឹតខំប្រឹងប្រែងអភិវឌ្ឍន៍ខ្លួនរហូតបានជោគជ័យនៅក្នុងសង្គម។*

*- នៅឆ្នាំ ១៩៩៥ បានរៀនគូររៀនឆ្លាក់ពីលោកគ្រូ ជិន គ័ង បន្ទាប់មកបានបន្តរៀនគូរក្បាច់ពីលោកព្រះគ្រូចៅអធិការវត្តពជបូព៌ ព្រះនាម ពិន សែម រយៈពេល៣ខែ។*

*- ឆ្នាំ២០០២ បានចាប់ផ្តើមបើកសិប្បកម្មចម្លាក់ស្បែកនៅជិតប្រាសាទបាគង ក្នុងខេត្តសៀមរាប ក្នុងគោលបំណងផ្សព្វផ្សាយមុខជំនាញសិល្បៈចម្លាក់ស្បែកដល់ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិឲ្យបានស្គាល់ពីទម្រង់សិល្បៈចម្លាក់ស្បែករបស់ខ្មែរយើង។*

*- បានបណ្តុះបណ្តាលសិស្សជាង១០០នាក់ បច្ចុប្បន្នពួកគាត់បានចេញប្រកបមុខរបរជំនាញសិល្បៈស្បែកនេះគ្រប់ទីកន្លែង។*

*- តាមរយៈស្នាដៃសិល្បៈទាំងឡាយ ក្រុមការងារចម្លាក់ស្បែករបស់យើងបានផ្សព្វផ្សាយជូននូវបទសម្ភាសន៍ជាច្រើនដល់បណ្តាញសារពត៌មាននានា ដូចជាតាមរយៈកាសែត វិទ្យុ និង ទូរទស្សន៍។ល។*

*- ស្បែកដែលបានដាប់ឆ្លាក់រាល់ថ្ងៃក្នុងរោងសិប្បកម្មនេះជាស្បែកសំរាប់ដាក់តាំងលំអ ពុំមែនជាស្បែកសម្រាប់សម្តែងទេ។*



*លោក ញ៉ឹក សេរីរតនា*


វិធីហាលស្បែក


វិធីហាលស្បែក



ចៀរស្បែកបន្ទាប់ពីហាលថ្ងៃ



រោងជាងធ្វើ សម្ភារៈសម្រាប់ធ្វាក់




ឧបករណ៍ចម្លាក់



ឧបករណ៍ចម្លាក់



ស្បែក ញញួរ ជ្រុញ អន្ទូទ ពន្ទក



ព្រាងរូបលើស្បែក



រៀនឆ្លាក់ស្បែកតូចៗ



សិស្សកំពុងឆ្លាក់



រូបដើមពោធិ៍





រូបឥន្ទជិតគង់លើដំរី



យមរាជដកស្រង់ពីប្រាសាទអង្គ



រូបមនុស្សជិះដំរី



ឥន្ទជិតប្រែកាឡាជាព្រះឥន្ទ្រ



ឥន្ទជិត



អប្សរា



ហ្មដំរី



សវនាការ



ហនុមានចែចង់នាងសុវណ្ណមច្ឆា



ព្រះរាមគង់ក្នុងព្រះពន្លា



ព្រះព្រហ្ម


គ្រួសារដំរី


គ្រួសារដំរី



ទេសភាពព្រៃភ្នំ



ព្រះលក្ស្មណ៍ចូលគាល់ព្រះរាម



បន្ទប់តាំងពិព័រណ៍ស្បែក




ពេងសិប្បកម្មសិល្បៈចម្លាក់ស្បែក ប្រាសាទបាគង

## IX. បច្ចេកទេសសិល្បៈចម្លាក់ស្បែក និងការសម្តែងសិល្បៈល្ខោនស្រមោលស្បែកធំ (គោកធ្លក)

### ក. បទបង្ហាញ

- ស្តីពីសកម្មភាពសិល្បៈទស្សនីយភាពរបស់សមាគមសិល្បករគោកធ្លក ដោយ **លោក កឿង កុម្ភៈ**
- សមាគមសិល្បករគោកធ្លកកើតនៅឆ្នាំ ២០១៧ មានសិល្បៈករសម្តែង ២៧នាក់។ បានសម្តែងជូនមហាជននៅតំបន់ដាច់ស្រ យាលចំនួន២៤ខេត្តក្រុង ក្នុងនោះមានការសម្តែងស្បែកធំ ស្បែកតូច និងពណ៌។ ស្បែកមានចំនួន៥០០ សន្ទឹក អាចសម្តែងបានរយៈពេល ៤-៣០ នាទី។
- ក្រុមការងារភាគច្រើនទាំង សិល្បករ ទាំងអ្នករដ្ឋបាល ជាអ្នកស្ម័គ្រចិត្ត។
- បច្ចុប្បន្ននេះយើងបានបង្កើតរោងសម្តែងនៅក្នុងបិវេណបណ្ណាល័យជាតិពោលគឺ នៅពេលដែលមានរោងសម្តែងគឺសកម្មភាពរបស់សមាគមនិងដំណើរការទៅមុខជានិរន្តរ។



លោក កឿង កុម្ភៈ

### ខ. គោកធ្លក

សមាគមសិល្បករគោកធ្លកបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៨ ក្នុងនោះមានសិល្បករ ២១នាក់ បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សិល្បករ ពហុជំនាញបានរួមគ្នាធ្វើអោយវិស័យសិល្បៈទស្សនីយភាពខ្មែរយើងរស់ឡើងវិញ នៅដើមស.វ ទី ២១នេះ។ បានសម្តែងជូនមហាជននៅតាមខេត្ត និងរាជធានីភ្នំពេញ ចំនួនជាង២០០លើក។

### គ. ទិសដៅ

- គោគធ្លកមានគោលបំណងចូលរួមភ្ជាប់ទំនាកទំនងសិល្បៈ និងការអភិវឌ្ឍន៍សង្គម ចូលរួមចំណែកថែរក្សារនូវប្រពៃណីមរតកសង្គមវប្បធម៌ជាតិដ៏សម្បូរបែប។
- ពង្រឹងនិង លើកកំពស់ការផ្សព្វផ្សាយ នូវសិល្បៈវប្បធម៌ជាតិដល់សហគមន៍ឲ្យបានទូលំទូលាយ។

### ឃ. ការបង្កើតស្នាដៃក្នុងរយៈពេល១០ឆ្នាំ

- ១០ ទម្រង់សិល្បៈសម្តែង និង៩ សាច់រឿងដកស្រង់ចេញពីអក្សរសិល្ប៍បុរាណខ្មែរ។
- ក្នុងឆ្នាំ ២០០៩ បានបង្កើតស្នាដៃសិល្បៈល្ខោនស្រមោលស្បែកធំ។
- ក្នុងឆ្នាំ២០០៩បានសម្តែងសល្បៈស្បែកពណ៌ ដែលសិល្បករយើងខកខានមិនបានសម្តែងនៅស្រុកខ្មែរយើងតាំងពីឆ្នាំ១៩៦០។

- ឆ្នាំ២០១០ បានសម្ដែងសិល្បៈល្ខោនប្រមោទ័យ។
- ឆ្នាំ២០១១ បានបង្កើតក្រុមដន្ត្រីស្គរ។
- ឆ្នាំ២០១២ បានបង្កើតរបាំឬស្សី។
- ឆ្នាំ២០១៣ បានបង្កើតស្បែកតូច រឿង ព្រះច័ន្ទគោរព។
- ឆ្នាំ២០១៤ បានបង្កើត ស្បែកធំរឿងរាមកេរ្តិ៍រយៈពេលសម្ដែង១ម៉ោង៤៥ នាទី។
- ឆ្នាំ២០១៦ បានបង្កើត ស្បែកធំរឿងរាមកេរ្តិ៍ រយៈពេល៤-៣០ នាទី។

## ង. ការសម្ដែងតាមខេត្តនានា

- មានដូចជា ខេត្ត តាកែវ សៀមរាប បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ កំពង់ស្ពឺ កណ្ដាល បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ធំ កំពង់ចាម ក្រចេះ រតនៈគីរី ស្វាយរៀង...។
- មានភ្ញៀវទស្សនាជាង១០០០នាក់។

## ច. ការសម្ដែងនៅរាជធានីភ្នំពេញ

- រាល់ស្នារដៃដែលបង្កើតថ្មី ត្រូវសម្ដែងមុនគេបង្អស់នៅរាជធានីភ្នំពេញ គឺក្នុងគោលបំណងចូលរួមចំណែកធ្វើឲ្យទីក្រុងមានភាពរស់រវើកផ្នែកវប្បធម៌។

## ឆ. ទម្រង់សិល្បៈសម្ដែង

- ស្បែកធំ ស្បែកពណ៌ ស្បែកតូច យីកេដំកង់ ល្ខោនចំរុះ របាំប្រពៃណី។ល។
- ចំណែកសិល្បៈស្បែកគឺយើងយកតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ។
- សិល្បករយើងចេះឆ្លាក់ស្បែក និងចេះសម្ដែង។
- ការសម្ដែងនៅឯបរទេសគឺយើងបានចេញទៅសម្ដែងនៅប្រទេសបារាំង សិង្ហបុរី និងប្រទេសដទៃទៀត។





សិម្ពលីគ្រុឌបំផ្លាញសរនាគកប្បាស



នាងសិតា



អង្គត់



ព្រះរាមផ្ទៃងសរ



ហនុមាននាំមហាជម្ពូទៅជួបព្រះរាម



សុគ្រីបគង់ក្នុងរាជវាំង



ហនុមាន ចាប់នាងសុវណ្ណមច្ឆា



ឥន្ទ្រជិតលាក់ខ្លួនក្នុងពពក



ព្រះនាងសិតាទ្រង់យាត្រា



ព្រះរាមទ្រង់យាត្រា



ព្រះនាងសិតា



ព្រះរាមតាំងសិល្ប៍



ព្រះរាមគង់ក្នុងព្រះពន្លា



ហនុមានចែចង់នាងសុវណ្ណមច្ឆា



សុគ្រីព ប្រយុទ្ធនិងពាលី



នាងសុបនាខា



រាពណ៍ចាប់នាងសិតា



ហនុមានប្រយុទ្ធជាមួយឥន្ទ្រជិត



ឥន្ទជិតទ្រង់ធ្វើពិធីតាំងសិល្ប៍



ស្បែកធំ សុគ្រីប និងពាលី



ពាលីប្រយុទ្ធ និងទូរភី



ហនុមានក្រាបបង្គំគាល់ព្រះរាម



ហនុមានយាង៍មហាជម្ពូ ឲ្យទៅចូលបង្គំគល់ព្រះរាម





ក្បួនទ័ពព្រះរាម



តួត្លុកកំប្លែង



ព្រះនាងតារាសោកសោកចំពោះការចូលទិវង្គតរបស់ព្រះស្វាមី



នេះកាលពាលីត្រូវសរព្រះរាម





ពិធីហោមរោង



សិល្បៈស្បែកតូច ឬរឿងព្រេងប្រជាប្រិយ



ស្បែកតូច ស្តីពីជីវភាពប្រជាជន



ត្លុកកំប្លែង



ប្រជល់ក្របី



រឿងអប់រំ



ពេជសម្តែង



ពេជសម្តែង





រៀនឆ្លាក់ស្បែក



ត្រៀមសម្ដែង

## X.បច្ចេកទេសសិល្បៈចម្លាក់ស្បែក និងការសម្តែងសិល្បៈល្ខោនស្រមោលស្បែកធំ (សិល្បៈសុវណ្ណភូមិ)

### *ក. ប្រវត្តិ*

*- លោក ម៉ាន់ កុសស កើតនៅឆ្នាំ ១៩៦១ នៅភូមិ ប្រនាងខ្ពស់ ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ។*

*- រៀនសាលាវិចិត្រ សិល្បៈ ឆ្នាំ ១៩៨៥*

*- ឆ្នាំ១៩៩១ ចូលបំរើការងារ នៅនាយកដ្ឋានសិល្បៈទស្សនីយភាព នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។*

*- ឯកទេសខាងស្បែកធំ (និងធ្វើស្បែកសម្តែង)*

*- បើកសមាគមសិល្បៈសុវណ្ណភូមិ ឆ្នាំ១៩៩៤ និងបន្តរហូតមកដល់បច្ចុប្បន្ន។*

*- ការសម្តែងៈ ក្នុងក្រុង រៀងរាល់ចុងសប្តាហ៍ ព្រមទាំង ចូលរួមសម្តែងសិល្បៈលំដាប់ជាតិ និង អន្តរជាតិ ជាញឹកញាប់។*

*- មានការសម្តែងល្ខោនខោល និងមានសិល្បករគ្រប់គ្រាន់សម្រាប់សម្តែង។*

### *ខ. រៀនឆ្លាក់ស្បែកតាមគំរូចម្លាក់ស្បែកចាស់ៗ*

*- ប្រើប្រាស់បច្ចេកទេសបុរាណ ដូចជា ស្បែកកណ្តាល ម្រេងភ្លើង ស្បែកគោ។*

*- ពន្លះហាលថ្ងៃសម្ងាប់ និង កំដៅថ្ងៃ រយៈពេល៣ ទៅ ៤ថ្ងៃទៅតាមកំដៅថ្ងៃ។*

*- កោសរោម និង កំបិតបន្ទួស។*

*- ព្រៀងរូប នឹងកំបោរ ឬដីស ។*

*- ឆ្លាក់ដាប់។*

*- កាត់សសៃពណ៌ខ្មៅ ជាមួយនិងដុំខ្មៅដុសចិន គាបឫស្សី ទៅតាមបច្ចេកទេស ។*

*គ្រូឯកទេស ចម្លាក់ស្បែកធំនិង សម្តែងល្ខោនស្រមោល*







ស្បែកហាលស្ងួត



កូនកាំបិតសម្រាប់ចៀរខ្លាញ់ សាច់ចេញពីស្បែក



ស្បែកគោត្រូវបានទិញពី កន្លែងសត្តឃាត



រៀបចំទាញបន្តឹងស្បែក



ទាញបន្តឹងស្បែក ភ្ជាប់ទៅនិងគ្រោងដែក



ទាញបន្តឹងស្បែក ភ្ជាប់ទៅនិងគ្រោងដែក



ចៀរសម្អាតស្បែក



ចៀរសម្អាតស្បែក



បាញ់ទឹកលាងសម្អាតធូលី



កាំបិតបន្ទួសសម្រាប់កោសរោមស្បែក



រៀបចំស្បែកហាលថ្ងៃ



ស្បែកស្ងួត



រៀបចំកោសសម្អាតរោមស្បែកចេញក្រោយពេលសម្ងួត



កោសសម្អាតរោមស្បែកចេញក្រោយពេលសម្ងួត



ស្បែកសម្ងាប់ហើយ





សម្ភារៈ សម្រាប់ឆ្លាក់ស្បែក



ដាប់ធ្វាក់រូបតូចៗ



ដាប់ធ្វាក់រូបតូចៗ



ព្រះរាមផ្ទៃងសរ



ហនុមានដើរ



ហនុមានសម្តែងឫទ្ធិ



អង្គត



អង្គត ហោះ



នាងបុញ្ញកាយហោះ



ឥន្ទជិតយាងចូលសមរភូមិជ័យ



ឥន្ទជិតយាងចូលសមរភូមិជ័យ



ពលយក្ស



សិម្ពលីគ្រុឌ បំផ្លាញសរ នាគកប្បាស ពីព្រះលក្ស្មណ៍



ក្រុងរាពណ៍គង់ក្នុងប្រាសាទ



ព្រះរាមផ្លែងសរ



ស្បែកត្រៀមសម្តែង



ស្បែកត្រៀមសម្តែង




រោងសម្តែងសិល្បៈ សុវណ្ណភូមិ



អសនៈសម្តេចព្រះគ្រូ



ការសម្តែងសិល្បៈល្ខោនស្រមោលស្បែកធំ រឿងរាមកេរ្តិ៍



ឈុតនាងបុញ្ញកាយប្រែកាឡាជាសពនាងសិតា



លើកទ័ពចូលសមរភូមិជ័យ



កាលព្រះលក្ស្មណ៍ត្រូវសរនាគកប្បាស



ឈុតលើកទ័ព



សិម្ពិលីគ្រុឌ យាងចុះមកជួយបំផ្លាញសរនាគកប្បាស



ខាងក្រោយឆាក



ខាងក្រោយឆាក



ចប់ការសម្តែង



ក្រុមតន្ត្រីករ

## XI. ទីផ្សារសិល្បៈចម្លាក់ស្បែក

*ក. ប្រវត្តិ*



- លោក ធឿក ដាវីត
- កើតនៅឆ្នាំ ១៩៨៦ ស្រុកក្រលាញ់ ខេត្តសៀមរាប
- រៀនចម្លាក់ពីសាលាបឋមសិក្សាវត្តរាជបូព៌ជាមួយឪពុកមា
- បានបើកកន្លែងសិប្បកម្មចម្លាក់ស្បែក ជាមួយឪពុកមានៅភ្នំពេញ។

*ខ. បទពិសោធន៍ការងារ*

- ជាមួយភ្ញៀវទេសចរណ៍
- ចាប់អារម្មណ៍លើចម្លាក់ស្បែក
- គោលបំណងចង់ផ្សព្វផ្សាយវប្បធម៌ និងគំនិតខ្មែរប្រឌិត
- ស្រលាញ់ និងមានចំណូលចិត្តឯកទេសស្បែក
- បញ្ហាប្រឈម ខ្វះការគាំទ្រ ទីផ្សារប្រគួតប្រជែង តម្លៃស្បែកឡើងថ្លៃ លក់បានថោក។



ចម្លាក់ចម្លងតាមជញ្ជាំង ប្រាសាទបាយ័ន



ព្រះរាម



ព្រះរាម



ព្រះរាមយាង៩ចូលសមរភូមិ



ហនុមាន



ហនុមាន



ហនុមាន







អប្សរា



ក្ងោក



ក្ងោក



ក្បាច់ផ្កាចាន់




សម្ភារៈសម្រាប់លំអភ្លើង



នាងសុវណ្ណមច្ឆា



ហនុមានចែចង់នាងសុវណ្ណមច្ឆា



រាជសីហ៍



អប្សរា



ហនុមាន



ដើមពោធិ



ព្រហ្មគង់លើហង្ស